# ដំណោះស្រាយ

## សំនួរសិក្សាទី ១

ចូរមើលរដ្ឋធម្មនុញ្ញកម្ពុជា និងរៀបរាប់អំពីមុខងាររបស់សភា (សភាជាតិ)!

១) ការតាក់តែងច្បាប់ (ដើម្បីប្រើអំណាចផ្នែកនីតិបញ្ញត្តិ) មាត្រា ៩០ I
- ក) ផ្តើមគំនិតបង្កើតច្បាប់ថ្មី មាត្រា៩១ I CC
- ខ) ធ្វើវិសោធនកម្មលើច្បាប់ជាធរមាន មាត្រា៩១ II CC

២) ការត្រួតពិនិត្យផ្នែកនីតិប្រតិបត្តិ
- ក) ជ្រើសតាំងអង្គការរដ្ឋផ្សេងៗ មាត្រា១១៩ I និង II CC
- ខ) សាកសួររដ្ឋាភិបាល មាត្រា៩៥ និង ៩៧ CC និងដាក់ញត្តិបន្ទោសទៅរដ្ឋាភិបាល មាត្រា៩៦ I CC
- គ) បណ្តេញសមាជិករដ្ឋាភិបាលចេញពីតំណែង ៩៨ CC
- ឃ) រៀបចំការចោទប្រកាន់លើសមាជិករបស់រដ្ឋាភិបាល មាត្រា១២៦ II និង III CC
- ង) អនុម័តលើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាល មាត្រា ៩០ II CC លើបញ្ហាដូចខាងក្រោម :
  - ថវិកា
  - ការលើកលែងទោស
  - អនុសញ្ញាអន្តរជាតិ
  - ការប្រកាសសង្គ្រាម ឬស្ថានភាពអាសន្ន មាត្រា៨៦ I CC

## សំនួរសិក្សាទី ២:

តើធាតុចំបងណាមួយនៃការធ្វើសេចក្តីសំរេចបែបប្រជាធិបតេយ្យ អាចត្រូវបានរកឃើញនៅក្នុងអត្ថបទសង្ខេបដែលដកស្រង់ចេញពីសារពត៌មាន The Cambodian Daily ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៣?

ធាតុចំបងនៃការធ្វើសេចក្តីសំរេចបែបប្រជាធិបតេយ្យនៅក្នុងអត្ថបទនេះគឺ:
តម្លាភាព និងការពិភាក្សាជាសាធារណ:

## សំនួរសិក្សាទី ៣:

ហេតុអ្វីបានជាអ្នកគិតថា សំណើរបស់ព្រះអង្គម្ចាស់ រណរិទ្ធ អាចបង្កើនគុណភាពការងាររបស់សភាជាតិ? (ដែលមានបញ្ជាក់នៅក្នុងអត្ថបទដែលដកស្រង់ចេញពីសារពត៌មាន The Cambodian Daily ចេញផ្សាយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣?)

ពីព្រោះថា ការធ្វើពង្រាងច្បាប់ ទាមទារឱ្យមានជំនាញការ និងអ្នកចូលរួមផ្សេងៗគ្នា ។ ការបង្កើតនូវអនុគណ:កម្មការ ជួយជំរុញល្បឿននៃដំណើរការតាក់តែងច្បាប់ ព្រោះថាគណ:កម្មការជំនាញទាំង ៩ របស់រដ្ឋសភាពុំអាចពិភាក្សាលើគ្រប់ប្រធានបទទាំងអស់នៅក្នុងពេលតែមួយនោះទេ ។

## សំនួរសិក្សាទី ៤

ក) ចូរអានរដ្ឋធម្មនុញ្ញកម្ពុជា និងរៀបរាប់អំពីដំណាក់កាលដើម្បីបង្កើតរដ្ឋាភិបាលថ្មី បន្ទាប់ពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រមក!

ការប្រកាសជាផ្លូវការនូវលទ្ធផលចុងក្រោយនៃការបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (NEC) មាត្រា ១១៨ LEMNA

**៦០ថ្ងៃក្រោយមក**

- គណបក្សឈ្នះឆ្នោតបង្កើតសំណើរមួយស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជាថ្មី មាត្រា១១៩ I ១ CC
- រដ្ឋាភិបាលក្នុងអំណាចបន្តដឹកនាំ "ការងារប្រចាំថ្ងៃ" ប៉ុន្តែ អំណាចមានកំណត់ មាត្រា៧៨ III ២ CC (ឧ. គ្មានសិទ្ធិផ្តួចផ្តើមច្បាប់ថ្មី ឬវិសោធនកម្មនៃច្បាប់ទេ)

**សម័យប្រជុំដំបូង**របស់រដ្ឋសភា មាត្រា៨២ I CC

- ជាមួយនឹងមតិភាគច្រើន២/៣ (៦៦.៦% នៃសន្លឹកឆ្នោត) រដ្ឋសភាអាចបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋាភិបាលថ្មី មាត្រា៨២ II CC
- រដ្ឋធម្មនុញ្ញ មិនបានចែងអំពីរយៈពេលកំណត់នៃការបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលថ្មីដោយរដ្ឋសភានោះទេ ។ ករណីនេះអាចនាំឱ្យមានភាពទាល់ច្រករយៈពេលវែងមួយនៅក្នុងប្រទេស ។

ខ) ប្រសិនណា មតិភាគច្រើន ២/៣ នៅក្នុងសភា មិនអាចដោះស្រាយនយោបាយទាល់ច្រកបាន តើអ្នកគិតថាគួរតែធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រង់ចំនុចណា ដើម្បីដោះស្រាយភាពទាល់ច្រកនោះ?

ដំណើរបង្អាក់នេះអាចត្រូវបានដោះស្រាយតាម **២ផ្លូវ:**

**វិសោធនកម្មនៃរដ្ឋធម្មនុញ្ញ** ដែលថា គ្រាន់តែមតិភាគច្រើនធម្មតា (៥០%+1 នៃសំលេងឆ្នោត) អាចមានអំណាចសំរេចអនុម័តជ្រើសរើសរដ្ឋាភិបាលថ្មីបាន ។

**បញ្ហា:** វិសោធនកម្មទាមទាឱ្យមានមតិភាគច្រើន ២/៣!

ឬ

វិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលថា ត្រូវមាន **ការបោះឆ្នោតជាថ្មី**

## សំនួរសិក្សាទី ៥

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនចង់ធ្វើការសំរុះសំរួលជាមួយនឹង "សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ" ដែលទើបតែបង្កើតឡើង ថ្មីៗនេះដោយគណបក្សហ្វុនស៊ិនប៉ិច និង សមរង្ស៊ី ។

ក) គាត់និយាយថា គណបក្សហ្វុនស៊ិនប៉ិច និងសមរង្ស៊ី មិនអាចឈរឈ្មោះនៅពេលបោះឆ្នោតជាពីរគណបក្សផ្សេងគ្នាពីដំបូង ហើយក្រោយពេលបោះឆ្នោត បែរជាមករួបរួមគ្នាជាបក្សតែមួយវិញ ដើម្បីធ្វើការចរចាបង្កើតរដ្ឋាភិបាលថ្មីមួយនោះទេ ។ លោកមានប្រសាសន៍ថា ករណីនេះផ្ទុយនឹងរដ្ឋធម្មនុញ្ញ ។

តើករណីនេះត្រូវ ឬខុស? សូមផ្ដល់មូលហេតុចំពោះគំនិតរបស់អ្នក និងបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផង!

លោកនាយករដ្ឋមន្ត្រី មានប្រសាសន៍មិនត្រឹមត្រូវទេ ។

- ពុំមានមាត្រាណាមួយនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ដែលហាមប្រាមគណបក្សនយោបាយមិនឱ្យបង្កើតក្រុមចំរុះក្រោយពីការបោះឆ្នោតនោះទេ ។ ផ្ទុយទៅវិញៈ ពួកគេដែលជាគណបក្សនយោបាយ អាចទាមទារសិទ្ធិបង្កើតសមាគម (មាត្រា៤២ I 1 CC) នៅពេលណាក៏បាន ។
- លើសពីនេះទៀតៈ មាត្រា១១៩ I 2 CC ចែងថា សមាជិកសភាម្នាក់នៃគណបក្សឈ្នះឆ្នោត ដែលត្រូវបានតែងតាំងដោយព្រះមហាក្សត្រ (មាត្រា១១៩ I ១ CC) ត្រូវដឹកនាំសមាជិកសភា ដែលជាសហការី ឬគណបក្សនយោបាយទាំងឡាយដែលមានអាសនៈនៅក្នុងសភា ដែលនឹងត្រូវបានដាក់ឱ្យកាន់តំណែងផ្សេងៗនៅក្នុងរាជរដ្ឋាភិបាល ដើម្បីសុំសន្លឹកឆ្នោតផ្ដល់សេចក្ដីទុកចិត្តពីសមាជិកសភាទាំងឡាយ ។ នេះបង្ហាញថា សមាជិកភាពនៅក្នុងរដ្ឋសភាមិនចាំបាច់ ត្រូវតែមានទំនាក់ទំនងជាមួយសមាជិកភាពនៅក្នុងគណបក្សនយោ-បាយ ណាមួយឡើយ ។
- មាត្រា ៧៧ I CC និងមាត្រា ៧៦ IV CC ក៏បង្ហាញផងដែរថា ប្រជាពលរដ្ឋខ្មែរគ្រប់រូប អាចឈរឈ្មោះឱ្យគេបោះឆ្នោតជាសមាជិកសភាបាន ។ វាមិនជាការចាំបាច់ទាល់តែសោះ ដែលសមាជិកសភាក៏ជាសមាជិករបស់គណបក្សនយោបាយដែរនោះ ។ សម្លេងឆ្នោតផ្ដល់សេចក្ដីទុកចិត្តដល់រដ្ឋាភិបាលថ្មី ដែលត្រូវបានស្នើឡើង គឺជាសេចក្ដីសម្រេចចិត្តរបស់សមាជិកសភា មិនមែនជាសេចក្ដីសម្រេចចិត្តរបស់គណបក្សនយោបាយឡើយ ។ សមាជិករដ្ឋសភា ដែលជាសមាជិករបស់គណបក្សនយោបាយផ្សេងៗគ្នា តែងតែអាចបង្កើតក្រុមសមាជិកសភាខ្លួនឯង ដើម្បីប្រមូលផ្ដុំសម្លេងឆ្នោតរបស់ពួកគេនៅក្នុងសភា ទោះបីជា គណបក្សរបស់ពួកគេបានរៀបចំយុទ្ធនាការដោយឡែកៗពីគ្នាសម្រាប់ការបោះឆ្នោតមុនក៏ដោយ ។

ខ) មន្ត្រីខ្លះនៃគណបក្សប្រជាជននិយាយថា ប្រទេសកម្ពុជា នឹងមិនអាចក្លាយជាប្រទេសប្រជាធិបតេយ្យបានទេ ប្រសិនណាមិនមានគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា ។ វាអាចនឹងផ្ទុយនឹងរដ្ឋធម្មនុញ្ញ ប្រសិនបើ គណបក្សទាំងបី (គណបក្សប្រជាជន ហ្វុនស៊ិនប៉ិច និងសមរង្ស៊ី) បង្កើតរដ្ឋាភិបាលចំរុះមួយ ។

តើករណីនេះត្រូវ ឬខុស? សូមផ្ដល់មូលហេតុចំពោះ គំនិតរបស់អ្នកផង និងបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផង!

ករណីនេះមិនត្រឹមត្រូវទេ ។ មិនមានមាត្រាណានៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាដែលចែងអំពីការផ្សំពាក្យទេ ។ មានតែពាក្យ "គណបក្សដែលឈ្នះឆ្នោត" ប៉ុណ្ណោះនៅក្នុងមាត្រា១១៩ I 1 CC ។ ប៉ុន្តែពាក្យនេះគ្រាន់តែមានន័យថា គណបក្សដែលសមាជិករបស់ខ្លួនភាគច្រើនបានឈ្នះអាសនៈសភាភាគច្រើនបំផុត នៅក្នុងការបោះឆ្នោតតែប៉ុណ្ណោះ ។ វាមិនបាននិយាយអ្វីអំពីគណបក្ស "ដែលចាញ់ឆ្នោត" ដែលត្រូវតែ ដើរតួនាទីជាគណបក្សប្រឆាំងទេ ។ មាត្រា១១៩ I ២ CC ក៏បង្ហាញផងដែរថា បេក្ខជនសមាជិកសម្រាប់រដ្ឋាភិបាលថ្មី អាចជ្រើសរើសក្នុងចំណោមសមាជិកសភា និងក្នុងចំណោមសមាជិកគណបក្សដែលមានអាសនៈនៅក្នុងសភាបាន ។ ប្រទេសលទ្ធិប្រជាធិបតេយ្យភាគច្រើនមានគណបក្សប្រឆាំង ប៉ុន្តែក៏អាចមានក្រុមចំរុះនៃគណបក្សទាំងអស់ ដើម្បីបង្កើតរដ្ឋាភិបាលផងដែរ ។ ប្រសិនបើ ពុំមានក្រុមជំទាស់នៅក្នុងសភាទេនោះ ការគ្រប់គ្រងជាសាធារណៈដោយប្រជាពលរដ្ឋ ដោយព្រឹទ្ធសភា ឬដោយក្រុមប្រឹក្សាធម្មនុញ្ញមានសារៈសំខាន់ច្រើន ។

## សំនួរសិក្សាទី ៦

ចូរអានអត្ថបទសង្ខេបដែលដកស្រង់ចេញពីសារពត៌មាន The Cambodian Daily ចេញផ្សាយថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០២ ដោយយកចិត្តទុកដាក់ ។

ក) តើមានគណៈកម្មការប៉ុន្មាននៅក្នុងរដ្ឋសភា? សូមកុំភ្លេចបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធ!

នៅពេលបច្ចុប្បន្ននេះ រដ្ឋសភាមានគណៈកម្មការចំនួន៩ (ប្រការ៦ ឃ្លាទី២ លេខ១-៩ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា)

ខ) តើសមាជិកសភា អាចបង្កើតគណៈកម្មការថ្មីដែលហៅថា "គណៈកម្មការព្រំដែនឯករាជ្យ" បានដែរឬទេ?
សូមកុំគ្រាន់តែឆ្លើយ "អាច" ឬ "មិនអាច" ប៉ុន្តែសូមផ្តល់នូវហេតុផលចំពោះគំនិតរបស់អ្នក និងបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផង!

ត្រឹមត្រូវហើយ ។ រដ្ឋសភាអាចបង្កើត "គណៈកម្មការដែលចាំបាច់ផ្សេងៗ" (មាត្រា៩៤ ឃ្លាទី១ CC) ។ សភាមានអំណាច ដើម្បីកំណត់មុខងាររបស់ខ្លួនផ្ទាល់ (ស្វយ័ត) ដោយបទបញ្ជាផ្ទៃក្នុង (មាត្រា៩៤ ឃ្លាទី២ CC) ។ ដូច្នេះ សភាអាចបង្កើតគណៈកម្មការបន្ថែមមួយទៀតបាន ដោយគ្រាន់តែកែប្រែបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនប៉ុណ្ណោះ ។ ១/៤ នៃសមាជិកសភា អាចលើកសំណើកែប្រែបទបញ្ជាផ្ទៃក្នុងបាន ។ បទបញ្ជាផ្ទៃក្នុងអាចធ្វើការកែប្រែបានដោយសម្លេងភាគច្រើន ២/៣ (សូមមើលបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ប្រការ៨២) ។

## សំនួរសិក្សាទី ៧

បន្ទាប់ពីឧបទ្ទវហេតុថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៣ មក ប្រធានគណៈកម្មាធិការកិច្ចការបរទេសនៃរដ្ឋសភា ម្ចាស់ក្សត្រី វិជ្ជរា បានអញ្ជើញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មកបង្ហាញខ្លួននៅសភាជាតិដើម្បីមកធ្វើជាកសិណសាក្សីអំពីឧបទ្ទវហេតុនេះ ។

ក) តើការកោះអញ្ជើញនេះអាចធ្វើទៅបានទេ បើយោងទៅតាមរដ្ឋធម្មនុញ្ញ ?
ពុំគ្រាន់តែឆ្លើយថា "អាច" ឬ "មិនអាច" ប៉ុណ្ណោះទេ ប៉ុន្តែបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផងដែរ!

អាចធ្វើទៅបាន ។ យោងតាមមាត្រា ៩៧ CC ដែលបានផ្តល់ឱ្យព្រះអង្គម្ចាស់ក្សត្រី វិជ្ជរា -ក្នុងនាមជាព្រះប្រធានគណៈកម្មការកិច្ចការបរទេស- អាចកោះហៅរដ្ឋមន្ត្រីជាន់ខ្ពស់បំផុតនៅក្នុងរដ្ឋាភិបាល គឺនាយករដ្ឋមន្ត្រីឱ្យបង្ហាញមុខបាន ។

**មាត្រា ៩៧ CC** ចែងថា :

"គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺ អំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។"

ខ) តើមធ្យោបាយណាផ្សេងដែលម្ចាស់ក្សត្រី អាចប្រើជំនួសការអញ្ជើញលោកនាយករដ្ឋមន្ត្រីមកបង្ហាញខ្លួននៅសភាជាតិបានទេ ?

ព្រះអង្គម្ចាស់ក្សត្រីអាចជ្រើសរើសលទ្ធភាពផ្សេងទៀតដូចតទៅនេះ :

- បញ្ចុះបញ្ចូល ១/១០ នៃសមាជិកសភា ឱ្យអញ្ជើញលោកនាយករដ្ឋមន្ត្រីមកបំភ្លឺអំពីឧបទ្ទវហេតុនោះ **មាត្រា៨៩** CC ។ នៅក្នុងករណីនេះព្រះអង្គម្ចាស់ក្សត្រី ត្រូវដើរតួជាសមាជិកសភាជាធម្មតាម្នាក់ ហើយមិនត្រូវដើរតួនាទីជាព្រះប្រធានគណៈកម្មការកិច្ចការបរទេសឡើយ ។
- ដាក់ញត្តិមួយប្រឆាំងរដ្ឋាភិបាល តាមរយៈព្រះប្រធានរដ្ឋសភា **មាត្រា ៩៦ I CC** ។
- បញ្ចុះបញ្ចូលឱ្យសមាជិករដ្ឋសភាចំនួន ៣០នាក់ ផ្សេងទៀត ផ្តួចផ្តើមគំនិតធ្វើញត្តិបន្ទោសមួយ **មាត្រា៩៨ I CC** ។
- ផ្តួចផ្តើមគំនិតធ្វើសេចក្តីសម្រេចមួយរបស់សភា តើត្រូវរៀបចំការចោទប្រកាន់លើសមាជិករដ្ឋាភិបាលម្នាក់ក្នុងចំណោមរដ្ឋាភិបាល ពីបទប្រព្រឹត្តិអំពើឧក្រិដ្ឋក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន (ត្រង់នេះ: ការញុះញង់ដោយសុន្ទរកថាមួយពាក់ព័ន្ធនឹងតួភាពយន្តថៃម្នាក់) **មាត្រា ១២៦ I និង II CC** ។

គ) តើអ្នកគិតថាហេតុអ្វីបានជាម្ចាស់ក្សត្រីអញ្ជើញ លោកនាយករដ្ឋមន្ត្រី មកបង្ហាញខ្លួននៅសភាជាតិ តែមិនអញ្ជើញ រដ្ឋមន្ត្រីក្រសួងការបរទេស ឬរដ្ឋមន្ត្រីដទៃៗទៀត?

ព្រះអង្គម្ចាស់ក្សត្រីបានអញ្ជើញលោកនាយករដ្ឋមន្ត្រី ពីព្រោះនៅក្នុងកិច្ចការនយោបាយ ដែលអាចប៉ះពាល់ប្រទេសជាតិទាំងមូល (ដូចជា កុប្បកម្មប្រឆាំងថៃ កាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៣) លោកនាយករដ្ឋមន្ត្រីមានកាតព្វកិច្ចរ៉ាប់រងលើការទទួលខុសត្រូវចុងក្រោយបំផុត លើគោលនយោបាយរួមរបស់រដ្ឋាភិបាល ។

**មាត្រា ៩៧ CC** ចែងថា :

"គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញ រដ្ឋមន្ត្រីមកបំភ្លឺ អំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។"

តើឃ្លាថា "ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន" មានន័យពិតប្រាកដដូចម្តេច?

**មាត្រា១២១ CC** បំពេញន័យឱ្យមាត្រា៩៧ ហើយបានចែងថា :

"សមាជិករដ្ឋាភិបាល ត្រូវទទួលខុសត្រូវរួមចំពោះរដ្ឋសភាលើគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ។

សមាជិករដ្ឋាភិបាលម្នាក់ៗ ត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រី និងរដ្ឋសភាលើការប្រព្រឹត្តិរបស់ខ្លួនផ្ទាល់ ។"

ឧទាហរណ៍ថា បើទោះបីជារដ្ឋមន្ត្រីក្រសួងការបរទេស និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាអ្នកទទួលខុសត្រូវលើបុព្វហេតុ និងផលវិបាកនៃកុប្បកម្មប្រឆាំងថៃក៏ដោយ ក៏វាជាការទទួលខុសត្រូវរួមរបស់នាយករដ្ឋមន្ត្រី ដើម្បីឆ្លើយបំភ្លឺអំពីឧបទ្ទវហេតុនោះចំពោះមុខរដ្ឋសភាដែរ ។

នៅក្នុងករណីដូចជាកុប្បកម្មប្រឆាំងថៃនេះជាដើម គោលនយោបាយរួមរបស់រដ្ឋាភិបាល ធ្វើឱ្យគេមានចម្ងល់ ពីព្រោះវាពាក់ព័ន្ធដល់វិស័យរសើបផ្នែកនយោបាយជាច្រើន មានជាអាទិ៍ កិច្ចការផ្ទៃក្នុង (សន្តិសុខសម្រាប់ប្រជាពលរដ្ឋ និងជនបរទេស) កិច្ចការបរទេស (ទំនាក់ទំនងការទូតនាពេលអនាគត ជាមួយប្រទេសថៃជាប្រទេសជិតខាង) កិច្ចការហិរញ្ញវត្ថុ (ថ្លៃចំណាយលើការសងជំងឺចិត្ត) និងកិច្ចការពាណិជ្ជកម្ម (ពាណិជ្ជកម្មជាមួយប្រទេសថៃនៅពេលអនាគត) ។ ដោយគេផ្តោតគោលដៅលើក្រសួងផ្សេងៗគ្នាជាច្រើន វាជាភារកិច្ចរបស់នាយករដ្ឋមន្ត្រី ដើម្បីឆ្លើយបំភ្លឺនូវសំណួរនានារបស់រដ្ឋសភា ។

**មាត្រា ១១៨ II CC** បំភ្លឺបញ្ហានេះ ដោយថែងថា :

"ទីស្តីការគណៈរដ្ឋមន្ត្រី <u>ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី</u>..."

វាជាអំណាចទូទៅរបស់នាយករដ្ឋមន្ត្រី ដើម្បីផ្តល់គោលការណ៍ណែនាំ និងដើម្បីបង្កើតនូវមូលដ្ឋានសំខាន់ៗនៃគោលនយោបាយបរទេស និងគោលនយោបាយក្នុងប្រទេស ជាពង្រាងមួយសម្រាប់របៀបវារៈផ្នែកនយោបាយរបស់រដ្ឋាភិបាលដែលគាត់ជាអ្នកទទួលខុសត្រូវ ។

## សំនួរសិក្សាទី ៨

សមាជិកសភាម្ចាស់ក្សត្រី វិជរ៉ា បាននិយាយនៅពេលសន្និសីទកាសែតឯសភាជាតិថា ម្ចាស់ក្សត្រីបានទទួលពត៌មាននាពេលប្រជុំនៅខុទ្ទកាល័យរដ្ឋាភិបាលថា លោកនាយករដ្ឋមន្ត្រីបាននិយាយថា លោកនឹងហៅម្ចាស់ក្សត្រីថា "នាង" ឬ "លោកជំទាវ" នៅពេលខាងមុខ ហើយលោកនឹងដាក់ម្ចាស់ក្សត្រីនៅគុកព្រៃសជាមួយ "ហ្វូងមនុស្ស" ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបដិសេធការចោទប្រកាន់ និងបាននិយាយថា យោបល់របស់ម្ចាស់ក្សត្រី មានបំណងបរិហារ ហើយលោកនឹងរៀបចំបណ្តឹងពីបទបរិហារប្រឆាំងនឹងម្ចាស់ក្សត្រី ។

តើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អាចប្តឹងម្ចាស់ក្សត្រីបានទេ ?

ពុំគ្រាន់តែឆ្លើយថា "អាច" ឬ "មិនអាច" ប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តល់<u>ហេតុផល</u>ចំពោះគំនិតរបស់អ្នក និងបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផងដែរ!

អាច ។ លោកនាយករដ្ឋមន្ត្រីអាចប្តឹងព្រះអង្គម្ចាស់ក្សត្រីបាន ប៉ុន្តែព្រះរាជអាជ្ញាមិនមានសិទ្ធិចោទប្រកាន់ព្រះអង្គម្ចាស់ក្សត្រីទេ ពីព្រោះព្រះនាងគឺជាសមាជិកសភា ហើយមាន<u>អភ័យឯកសិទ្ធិរបស់សភា</u> ។

**មាត្រា ៨០ I និង II CC**

នេះមានន័យថា ព្រះអង្គម្ចាស់ក្សត្រីអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ (ចោទប្រកាន់ ចាប់ខ្លួន ឬឃុំខ្លួន) ចំពោះអំពើឧក្រិដ្ឋបាន ប្រសិន<u>បើមានការយល់ព្រមចំនួន២/៣ នៃរដ្ឋសភា</u> **មាត្រា ៨០ III និង IV CC** ។

អភ័យឯកសិទ្ធិសភាធានានូវលទ្ធភាពនៃការពិភាក្សាជាចំហ និងដោយសេរីនៅក្នុងសភា ដោយការពារតំណាងរាស្ត្រទាំងឡាយ នៅពេលដែលពួកគេបញ្ចេញមតិរបស់ខ្លួន ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យដ៏រស់រវើក ការពិភាក្សាដ៏សកម្មក្នុងចំណោមអ្នកធ្វើច្បាប់មានសារៈសំខាន់យ៉ាងខ្លាំង ។ ការពិភាក្សា និងការដេញដោលគ្នានឹងត្រូវជាប់គាំងនៅមួយកន្លែង បើអ្នកធ្វើច្បាប់ត្រូវធ្វើការសុំទោស បន្ទាប់ពីការវាយប្រហារតាមពាក្យសម្តីម្តងៗ ដែលពួកគេធ្វើឡើង ឬត្រូវតែភ័យខ្លាចរបួតចំពោះផលវិបាកផ្សេងៗ មុនពេលពួកគេផ្តល់យោបល់លើអ្វីមួយនោះ ។

## សំនួរសិក្សាទី ៩

មាត្រាមួយនៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា សម័យប្រជុំរបស់សភាអាចយកជាបានការ នៅពេលដែលចំនួនសមាជិកសភាអប្បបរមាមួយបានចូលរួមប្រជុំ ។

ចូរបញ្ជាក់អំពីមាត្រានេះឱ្យបានច្បាស់លាស់ និង ចំនួនសមាជិកសភាប៉ុន្មាននាក់ ដែលត្រូវមានវត្តមាន។

**មាត្រា ៨៨ III CC** ចែងថា : " ការប្រជុំរដ្ឋសភា នឹងយកជាការបាន លុះត្រាតែមាន កូរ៉ុម ៧/១០ នៃសមាជិករដ្ឋសភាទាំងមូល "។

## សំនួរសិក្សាទី ១០

សមាជិកសភាអាចអវត្តមាននៅពេលប្រជុំសភាបាន ចំពោះមូលហេតុមួយចំនួនជាកំណត់ប៉ុណ្ណោះ ។

ចូររៀបរាប់អំពីមូលហេតុ**ទាំងអស់**នោះ និងបញ្ជាក់ពីគោលការណ៍ដែលមានចែងនៅបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។

សមាជិកសភាអាចអវត្តមាន លុះត្រាតែមានការអនុញ្ញាតពីប្រធានរដ្ឋសភា (ប្រការ៦៧ នៃបទបញ្ជាផ្ទៃក្នុង)

ការអនុញ្ញាត អាចផ្តល់ឱ្យបានចំពោះហេតុផលណាមួយក្នុងចំណោមហេតុផលខាងក្រោម :

- **ការឈប់សំរាកធម្មតា :**
  - ១៥ ថ្ងៃដោយមានការអនុញ្ញាតពីប្រធានសភា (ប្រការ៦៨ ប្រយោគទី ១ នៃបទបញ្ជាផ្ទៃក្នុង)
  - លើសពី១៥ថ្ងៃ ដោយមានការឯកភាពពីសភា (ប្រការ៦៨ ប្រយោគទី ២ នៃបទបញ្ជាផ្ទៃក្នុង)
- **ការឈប់សំរាកពេលមានជំងឺ :** លើសពី៥ថ្ងៃបាន ប្រសិនបើមានលិខិតបញ្ជាក់ពីគ្រូពេទ្យ (ប្រការ៦៩ នៃបទបញ្ជាផ្ទៃក្នុង)

## សំនួរសិក្សាទី ១១

ចូររៀបរាប់អំពីទោសផ្សេងៗចំពោះអវត្តមានមិនត្រឹមត្រូវនៃសមាជិកសភា ។

ចាប់ផ្តើមរាយរាប់ពីទោសស្រាលបំផុតឡើងទៅ និងបញ្ចប់ដោយទោសធ្ងន់បំផុត ("គោលការណ៍នៃភាពសមាមាត្រ") ។

កុំភ្លេចបញ្ជាក់អំពីប្រការនៃបទបញ្ជាផ្ទៃក្នុងរបស់សភាជាតិផង!

**១) អវត្តមានលើសពីថ្ងៃអវត្តមានដែលមានការអនុញ្ញាត :**

កាត់ប្រាក់លើកទឹកចិត្តតាមចំនួនថ្ងៃដែលអវត្តមាន (ប្រការ៧១ នៃបទបញ្ជាផ្ទៃក្នុង)

**២) អវត្តមានចំនួន៣ ថ្ងៃដោយគ្មានការអនុញ្ញាត**

កាត់ប្រាក់បំណាច់តាមចំនួនថ្ងៃដែលអវត្តមាន (ប្រការ៧០ នៃបទបញ្ជាផ្ទៃក្នុង)

**៣) អវត្តមានដែលមិនអាចអធ្យាស្រ័យបានទោះបីជាមានលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរ**

ក) អវត្តមានចំនួនពីរថ្ងៃៈ ព្រមាន (ប្រការ៧២ I ក)

ខ) អវត្តមានទោះបីជាមានការព្រមានៈ កាត់ប្រាក់លើកទឹកចិត្ត ( ប្រការ៧២ I ខ)

គ) អវត្តមានទោះបីមានវិធានការវិន័យៈ
កាត់ប្រាក់បៀវត្ស និងហាមមិនឱ្យចូលប្រជុំចំនួន ១៥ ថ្ងៃ ( ប្រការ៧២ I គ)

ឃ) អវត្តមានទោះបីជាមានសកម្មវិន័យចំនួនបីលើកៈ
- កាត់ប្រាក់បៀវត្ស និង
- បញ្ឈប់ការងាររយៈពេលមួយខែ ហើយប្រកាសផ្សាយដំណឹងដល់ប្រជាជន ដែលរស់នៅក្នុងមណ្ឌលរបស់គាត់ ។

## សំនួរសិក្សាទី ១២

តំណាងគណបក្សនយោបាយនៅក្នុងសភា មានសិទ្ធិទទួលបាននូវសេរីភាពក្នុងការបង្កើតសមាគម ។

ក) ចូរដកស្រង់នូវបទបញ្ញត្តិជាតិ និងអន្តរជាតិ ( មាត្រា) ដែលការពារសេរីភាពក្នុងការបង្កើតសមាគម ។

មាត្រា៣៦ V និង មាត្រា៤២ I ១ CC ( រដ្ឋធម្មនុញ្ញកម្ពុជា)

មាត្រា២២ I ICCPR ( កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ)

មាត្រា១៤ II ង CEDAW ( អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ)

មាត្រា១ I CRC ( អនុសញ្ញាស្តីពីសិទ្ធិកុមារ)

ខ) តើអ្វីជាភាពខុសគ្នារវាងសេរីភាពខាងការជួបប្រជុំ និងសេរីភាពក្នុងការបង្កើតសមាគម ?

ការប្រមូលផ្តុំគ្នា មានន័យថា ប្រជាពលរដ្ឋគ្រាន់តែជួបជុំ និងប្រមូលផ្តុំគ្នានៅតាមផ្លូវ ឬនៅក្នុងបន្ទប់មួយ ដោយពុំមានរចនាសម្ព័ន្ធអង្គការចាត់តាំង (អង្គការលេខ) ឬគោលបំណងរយៈពេលយូរ ។ ឧទាហរណ៍ ពួកគេគ្រាន់តែជួបជុំគ្នា ដើម្បីពិភាក្សាអំពីបញ្ហាអ្វីមួយ ឬធ្វើបាតុកម្មជាសាធារណៈមួយ ដោយដើរដង្ហែក្បួននៅតាមដងផ្លូវតែប៉ុណ្ណោះ ។

ការបង្កើតសមាគម មានន័យថា ប្រជាពលរដ្ឋអាចចូលរួមជាមួយគ្នា សម្រាប់គោលបំណងរយៈពេលយូរ និង មានរចនាសម្ព័ន្ធអង្គការចាត់តាំងត្រឹមត្រូវ ។ ឧទាហរណ៍ ពួកគេបង្កើតអង្គការក្រៅរដ្ឋាភិបាល ឬសមាគមនិស្សិត ។

គ) តើអ្វីទៅជាការដាក់កំហិតលើសេរីភាពក្នុងការបង្កើតសមាគម? ចូរដកស្រង់នូវមាត្រាជាតិ និង អន្តរជាតិដែលពាក់ព័ន្ធ!

មាត្រាពិសេសស្តីពីសេរីភាពក្នុងការបង្កើតសមាគម ( មាត្រា៤២ I ២ CC) មិនកំណត់នូវការដាក់កំហិតណាមួយទេ ។ ដូច្នេះ គេត្រូវតែអនុវត្តមាត្រាទូទៅស្តីពីការដាក់កំហិត ។ មាត្រា៣១ II ២ CC ចែងថា សិទ្ធិសេរីភាពណាមួយអាចដាក់កំហិតបាន ដើម្បីការពារ **"សិទ្ធិសេរីភាពរបស់អ្នកដទៃ"** ។

មាត្រា២២ II ១ ICCPR ចែងថា សេរីភាពក្នុងការបង្កើតសមាគមអាចត្រូវដាក់កំហិតដើម្បីការពារៈ

- សន្តិសុខជាតិ
- សុវត្ថិភាព ឬសណ្តាប់ធ្នាប់សាធារណៈ
- សុខភាព ឬសីលធម៌សាធារណៈ

មាត្រា៤ ខ CERD (អនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងពូជសាសន៍) ចែងថា រាល់អង្គការដែលប្រកាន់ពូជសាសន៍ទាំងអស់ត្រូវហាមឃាត់ ។

## សំនួរសិក្សាទី ១៣

ក) តើបុព្វកថានៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សបាននិយាយអ្វីខ្លះអំពី "នីតិរដ្ឋ" ?

បុព្វកថានៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (UDHR) បានចែងនៅក្នុងផ្នែកទីពារបស់ខ្លួនថា មុខងារដ៏សំខាន់បំផុតរបស់"នីតិរដ្ឋ" គឺត្រូវការពារសិទ្ធិមនុស្ស ។ (ដើម្បីកុំឱ្យមនុស្សត្រូវបានគេបង្ខំនៅទីបំផុត ឱ្យចាប់ផ្តើមការបះបោរប្រឆាំងលទ្ធិផ្តាច់ការ និងការគាបសង្កត់) ។

ខ) តើមាត្រា២៩ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និយាយអ្វីខ្លះអំពីមុខងាររបស់ច្បាប់? សូមដកស្រង់ ឱ្យបានច្បាស់លាស់ និងផ្តល់នូវការពិណនាសង្ខេបអំពីមុខងាររបស់ច្បាប់!

មាត្រា២៩ ចំនុចទី២ នៃ UDHR ចែងថា សិទ្ធិសេរីភាពទាំងអស់របស់មនុស្សអាចត្រូវបានកំណត់ (ដាក់កំហិត) បានដោយច្បាប់តែប៉ុណ្ណោះ ។

ការដាក់កំហិតដោយច្បាប់បែបនេះ អាចសមស្របជាមួយសិទ្ធិមនុស្សបាន លុះត្រាច្បាប់នេះមាន **គោលបំណង ដើម្បីការពារ :**

- ការគោរព និងការទទួលស្គាល់**សិទ្ធិសេរីភាពរបស់អ្នកដទៃ**
- លក្ខខណ្ឌតម្រូវ**ផ្នែកសីលធម៌**ត្រឹមត្រូវ
- **សណ្តាប់ធ្នាប់សាធារណៈ**
- **សុខុមាលភាពទូទៅ**នៅក្នុងសង្គមប្រជាធិបតេយ្យ ។

## សំនួរសិក្សាទី ១៤

បណ្តាបទដ្ឋានគតិយុត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជាដែលអនុម័តដោយរដ្ឋសភាហើយ ត្រូវតែស្របទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

សូមធ្វើការដកស្រង់ឱ្យបានច្បាស់លាស់(!) យ៉ាងតិចឱ្យបាន២មាត្រា នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដែលបង្ហាញថា បទដ្ឋានគតិយុត្តិទាំងនោះត្រូវតែមានធម្មនុញ្ញភាព ។

**មាត្រា១៥០ II CC**ចែងថា រាល់ច្បាប់ទាំងអស់ត្រូវតែមានលក្ខណៈស្របទៅតាមរដ្ឋធម្មនុញ្ញដាច់ខាត ។

**មាត្រា១៣៦ I CC** ចែងថា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែការពារ ការគោរពរដ្ឋធម្មនុញ្ញ និងពិនិត្យមើលច្បាប់ទាំងឡាយដែលត្រូវបានអនុម័តដោយរដ្ឋសភា ។

**មាត្រា១៤០ II ២ CC** ចែងថា មុនការប្រកាសឱ្យប្រើប្រាស់ច្បាប់ទាំងនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចសម្រេចថា ពង្រាងច្បាប់ ដែលត្រូវបានអនុម័តដោយរដ្ឋសភាហើយនោះ ត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញដែរ ឬអត់ ។

**មាត្រា១៤១ I CC** ចែងថា ក្រុមប្រឹក្សាធម្មនុញ្ញ អាចពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើហើយ ។

**មាត្រា១៤១ II CC** ចែងថា ក្រុមប្រឹក្សាធម្មនុញ្ញអាចសម្រេចអំពី ការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងធម្មនុញ្ញ-ភាព របស់ច្បាប់បាន ។

**មាត្រា១៤២ I CC** ចែងថា បញ្ញត្តិនានានៅក្នុងមាត្រាណាមួយ ដែលក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថាមិនសមស្របតាមរដ្ឋធម្មនុញ្ញ មិនត្រូវអនុវត្ត ឬប្រកាសឱ្យប្រើប្រាស់ឡើយ ។

ដូច្នេះ អ្នកបង្កើតច្បាប់ជាក់ស្តែងមានភារកិច្ច ដើម្បីអនុម័តតែច្បាប់ទាំងឡាយណាដែលសមស្របជាមួយរដ្ឋធម្មនុញ្ញប៉ុណ្ណោះ ។

## សំនួរសិក្ខាទី ១៥

បណ្តាបញ្ហាសំខាន់ៗនៅក្នុងសង្គម ត្រូវតែដោះស្រាយ និងបញ្ញត្តិ ដោយច្បាប់ ។ សូមធ្វើការដកស្រង់ឱ្យបានច្បាស់លាស់ នូវមាត្រាចំនួន ប្រាំ ចេញពីផ្នែកនៃមាត្រា៣១ ដល់ មាត្រា៥០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជា-ណាចក្រកម្ពុជា ដែលចែងច្បាស់ថាបញ្ហាណាមួយ"ត្រូវកំណត់ដោយច្បាប់" ។

| | |
|---|---|
| **មាត្រា៣៣ III CC:** | សញ្ជាតិខ្មែរត្រូវបានកំណត់ដោយច្បាប់ |
| **មាត្រា៣៤ V CC:** | បញ្ញតិនានាដែលដាក់កំហិតលើសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យត្រូវបានកំណត់នៅក្នុងច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។ |
| **មាត្រា៣៦ IV CC:** | សិទ្ធិក្នុងការទទួលបានសន្តិសុខសង្គម ឬអត្ថប្រយោជន៍សង្គមដទៃទៀត ត្រូវបានកំណត់ដោយច្បាប់ ។ |
| **មាត្រា៣៦ VI CC:** | ការបង្កើតសហជីពកម្មករត្រូវបានកំណត់ដោយច្បាប់ ។ |
| **មាត្រា៣៧ CC:** | សិទ្ធិធ្វើកូដកម្ម/បាតុកម្មអហិង្សា ត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌច្បាប់ ។ |
| **មាត្រា៤១ II CC:** | របបបណ្តាញសាព័តិមានត្រូវបានកំណត់ដោយច្បាប់ ។ |
| **មាត្រា៤២ I ២ CC:** | សិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ត្រូវបានកំណត់ដោយច្បាប់ ។ |
| **មាត្រា៤៤ II CC:** | កម្មសិទ្ធិឯកជនផ្លូវច្បាប់ត្រូវបានការពារដោយច្បាប់ ។ |
| **មាត្រា៤៩ II ២ CC:** | ភារកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដើម្បីការពារមាតុប្រទេសត្រូវបានកំណត់ដោយច្បាប់ ។ |

## សំនួរសិក្ខាទី ១៦

ក) តើបំរាមរបស់រដ្ឋាភិបាលទៅលើគ្រូបង្រៀនពិការ បានដាក់កំហិតលើសិទ្ធិមួយណា?
ចូរបញ្ជាក់ពីសិទ្ធិទាំងនោះ និងមាត្រាច្បាប់ជាតិ និងអន្តរជាតិ!

ការហាមប្រាមរបស់រដ្ឋាភិបាលទៅលើគ្រូបង្រៀនជនពិការដាក់កំហិតលើសិទ្ធិដូចតទៅៈ

- **សេរីភាពវិជ្ជាជីវៈ**
  - មាត្រា៣៦ I CC
  - មាត្រា៦ I កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងនយោបាយ (ICESCR)
  - មាត្រា៧ ប្រយោគទី២ សេចក្តីប្រកាសស្តីពីសិទ្ធិជនពិការ (DRDP)
  - មាត្រា២៣ លេខ១ UDHR
- **សិទ្ធិមិនរើសអើង** (សិទ្ធិទទួលបានការប្រព្រឹត្តិដោយស្មើគ្នា)
  - មាត្រា៣១ II រដ្ឋធម្មនុញ្ញកម្ពុជា (CC)
  - មាត្រា២៦ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)
  - មាត្រា១ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (UDHR) មាត្រា ២ លេខ១ UDHR
- **សេរីភាពធ្វើសកម្មភាព :**
  - មាត្រា៣២ I CC ("សិទ្ធិទទួលបានសេរីភាពផ្ទាល់ខ្លួន")
  - មាត្រា៣ UDHR

ខ) សូមបើកមើលគេហទំព័រដូចខាងក្រោម :

ចូលទៅ www.online.com.kh/user/kid,

→ បន្ទាប់មក "**Related Link**"

→ រួច "**International Institutions and Law Texts of International Constitutions and Treaties**"

→ បន្ទាប់មកទៀត "**University of Minnesota**"

→ រួចហើយ "**Treaties and other Instruments organized by subject matter**"

→ និងចុងបញ្ចប់ "**Disabled Persons**"

សូមរកសេចក្តីប្រកាសអង្គការសហប្រជាជាតិ ដែលគ្របដណ្តប់ករណីគ្រូបង្រៀនដែលរៀបរាប់ខាងលើ និងតើមាត្រានៃសេចក្តីថ្លែងការណ៍ណាមួយដែលជាប់ពាក់ព័ន្ធ - សូមធ្វើការដកស្រង់តែមាត្រាមួយបានហើយ!

មាត្រា៧ ឃ្លាទី២ DRDP

## សំនួរសិក្សាទី ១៧

រាជរដ្ឋាភិបាលចង់ធ្វើការប្រមូលលុយពីអ្នកបើកបររថយន្តទាំងឡាយ ដែលប្រើប្រាស់ផ្លូវជាតិ ។ តើករណីនេះចាំបាច់ដែរឬទេដែលថា ការប្រមូលលុយថ្លៃផ្លូវបែបនេះ ត្រូវកំណត់ដោយច្បាប់ដែលអនុម័តដោយរដ្ឋសភា? ឬក៏រាជរដ្ឋាភិបាលអាចសំរេចបញ្ហានេះដោយមិនចាំបាច់មានច្បាប់ ?

សូមផ្តល់នូវមូលហេតុតាមផ្លូវច្បាប់សំរាប់ចំលើយនេះ!

វាចាំបាច់ត្រូវមានច្បាប់មួយ ដែលអនុញ្ញាតឱ្យមានការប្រមូលថ្លៃប្រើប្រាស់ផ្លូវ ។ ហេតុផលគឺថា យោងតាមគោលការណ៍នៃការបែងចែកអំណាច (មាត្រា៥១ III ២ និង IV CC) សេចក្តីសំរេចសំខាន់ៗ ត្រូវតែធ្វើក្នុងទំរង់ដូចច្បាប់ដែលអនុម័តដោយសមាជិកសភាក្នុងនាមជាតំណាងរាស្ត្រ ហើយមានតែបទបញ្ជាដែលពាក់ព័ន្ធនឹងការងាររដ្ឋបាលតូចតាចប៉ុណ្ណោះ ដែលទុកឱ្យសំរេចដោយអង្គនីតិបញ្ញត្តិ ។ ការប្រមូលថ្លៃប្រើប្រាស់ផ្លូវ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះ មជ្ឈដ្ឋានរស់នៅ ទ្រព្យសម្បត្តិ និងធនធានសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជា ក៏ដូចជា សិទ្ធិរបស់ពួកគេក្នុងការដើរហើរដោយសេរីនៅក្នុងប្រទេសរបស់ខ្លួន និងក្នុងការធ្វើអាជីវកម្ម (មាត្រា៤០ I CC: សេរីភាពក្នុងការដើរហើរ មាត្រា៤៤ I ១ និង II CC: សិទ្ធិលើទ្រព្យសម្បត្តិឯកជន មាត្រា៣៦ I CC: សិទ្ធិក្នុងការប្រកបរបរអាជីវកម្មដោយសេរី) ។ ដូច្នេះ ការដាក់កំហិតផ្នែកសេដ្ឋកិច្ចទៅលើសិទ្ធិទាំងនេះ ត្រូវតែមានចែងនៅក្នុងច្បាប់ ។

## សំនួរសិក្សាទី ១៨

សូមធ្វើការស្រមៃថា អ្នកច្បាប់បានពង្រាងច្បាប់ថ្មីមួយ "ច្បាប់ស្តីពីចរាចរនៃរថយន្តតាមផ្លូវសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា" ។

តើវាមានធម្មនុញ្ញភាពដែរឬទេ ប្រសិនបើអ្នកច្បាប់ទាំងនោះបានអនុម័តមាត្រាមួយនៃច្បាប់នោះ ដែលមានអត្ថន័យដូចខាងក្រោម :

> "រថយន្តទាំងឡាយ ត្រូវតែមានលេខអាជ្ញាប័ណ្ណ ។ ព័ត៌មានលំអិតស្តីពីទំហំ ពណ៌ និង លំដាប់លេខអាជ្ញាប័ណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យក្រសួងសាធារណការ និង ដឹកជញ្ជូន? "

សូមផ្តល់នូវមូលហេតុតាមផ្លូវច្បាប់សំរាប់ចំលើយរបស់អ្នក!

ពិតណាស់ វាអាចនឹងស្របរដ្ឋធម្មនុញ្ញ ។ វាមិនបំពាននឹងគោលការណ៍នៃការបែងចែកអំណាចទេ (មាត្រា៥១ III ២ និង IV CC ) ប្រសិនបើ សមាជិកសភាប្រតិភូអំណាចធ្វើច្បាប់ទៅឱ្យអង្គនីតិបញ្ញត្តិ ពីព្រោះនៅក្នុងករណីនេះ ការសំរេចសំខាន់ៗអំពីភាពចាំបាច់នៃផ្លាកលេខឡាន ដែលប៉ះពាល់ដល់សេរីភាពរបស់អ្នកបើកបរដែលចង់ធ្វើអ្វីៗដែលពួកគេចង់ធ្វើ (មាត្រា៣១ I និង II CC) ត្រូវបានធ្វើដោយសមាជិកសភាដែលបញ្ជាក់នៅក្នុងឃ្លាទី ១ នៃមាត្រាខាងលើ ។ មានតែបទបញ្ញត្តិដែលពាក់ព័ន្ធនឹងបច្ចេកទេសតូចតាចដែលមិនប៉ះពាល់ដល់សេរីភាពប៉ុណ្ណោះទេ ដែលត្រូវទុកឱ្យអង្គនីតិបញ្ញត្តិជាអ្នកកំណត់ ។ បញ្ញត្តិត្រឹមសេចក្តីលំអិតទាំងនោះ វាសមរម្យ ព្រោះថា វានឹងមិនមែនជាការរំខានដល់សមាជិកសភាជាមួយនឹងបញ្ហាតូចតាចនេះ ហើយអត្ថបទច្បាប់នឹងមិនវែងពេកដែរ ។

## សំនួរសិក្សាទី ១៩

ពុទ្ធសាសនិកកម្ពុជាភាគច្រើនមានអារម្មណ៍ថាត្រូវបានរំខានដោយ បេសកជនគ្រីស្តបរិស័ទបរទេស ដែលមកផ្ទះពួកគាត់ ហើយគោះទ្វារ និងព្យាយាមបញ្ចុះបញ្ចូលពួកគាត់ឱ្យក្លាយជាគ្រីស្តបរិស័ទ ។

សូមធ្វើការស្រមៃថា អ្នកច្បាប់បានអនុម័តនូវ "ច្បាប់ស្តីពីសកម្មភាពរបស់សាសនទូត" ដែលរួមមានមាត្រាមួយដែលមាន អត្តន័យដូចខាងក្រោម:

"ផ្នែកទី ១: ច្បាប់នេះ មានគោលដៅក្នុងការការពារសន្តិភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា ។
ផ្នែកទី២: រាល់សកម្មភាពគ្រីស្តបរិស័ទទាំងឡាយ ដែលរស់នៅប្រទេសកម្ពុជា (ដោយមិនកំណត់ថាសកម្មភាពនោះ អនុវត្តនៅពេលណា ដោយមធ្យោបាយអ្វីនោះទេ) ត្រូវហាមឃាត់ជាដាច់ខាត ចាប់ពីថ្ងៃនេះតទៅ ។"

តើមាត្រានៃច្បាប់ដែលបានពោលខាងលើនេះ មានធម្មនុញ្ញភាពដែរឬទេ ? សូមផ្តល់នូវមូលហេតុតាមផ្លូវច្បាប់ សំរាប់ចំលើយរបស់អ្នក!

ច្បាប់នោះនឹងមិនស្របតាមរដ្ឋធម្មនុញ្ញ :

១) ពីព្រោះ**គោលបំណងនៃការដាក់កំហិត** (គោលបំណងនៃច្បាប់នេះដូចបានកំណត់នៅក្នុងផ្នែកទី I) **មិនស្របរដ្ឋធម្មនុញ្ញ** ពីព្រោះអ្នកធ្វើច្បាប់មិនត្រូវបានអនុញ្ញាតឱ្យដាក់កំហិតសេរីភាពសាសនា ដោយគ្រាន់តែដើម្បីការពារ "សេចក្តីសុខនៃជីវិតប្រចាំថ្ងៃ" តែប៉ុណ្ណោះ ។

២) ឬ ពីព្រោះ**ការដាក់កំហិត**នោះ (ដូចបានកណត់ក្នុងផ្នែកទី II នៃច្បាប់នេះ) **មិនសមាមាត្រគ្នា** ដោយសារវាមិនចាំបាច់សម្រាប់ការការពារសិទ្ធិរបស់អ្នកដទៃ ដើម្បីដាក់កំហិតលើសកម្មភាពសាសនាទាំងអស់ ដោយមិនគិតថាតើសកម្មភាពទាំងនេះបង្កគ្រោះថ្នាក់ដល់សិទ្ធិអ្នកដទៃឬក៏អត់ ឡើយ ។

ដោយពិស្តារ :

**តើសិទ្ធិមនុស្សមួយណាដែលត្រូវបានប៉ះពាល់ដោយច្បាប់នេះ?**

ច្បាប់នេះប៉ះពាល់ដល់សេរីភាពផ្នែកជំនឿសាសនារបស់សាសនទូតបរទេស ។ សេរីភាពនេះរួមមានសេរីភាពក្នុងការអនុវត្តន៍សាសនា និងកិច្ចពិភាក្សាអំពីសាសនាដែលនឹងមានសមាជិកថ្មី ។

ដោយមាត្រា ៤៣ I CC គ្រាន់តែផ្តល់សេរីភាពសាសនាដល់"ប្រជាពលរដ្ឋខ្មែរ"ប៉ុណ្ណោះ នោះសាសនទូតបរទេស មិនត្រូវបានការពារដោយមាត្រានេះទេ ប៉ុន្តែពួកគេអាចទាមទារសេរីភាពខាងសាសនា យោងតាមមាត្រា ១៨ I ១ ICCPR ដែលផ្តល់សេរីភាពនេះដល់មនុស្ស"គ្រប់រូប" ។ បទបញ្ញារបស់ ICCPR ក៏ជាផ្នែកមួយនៃច្បាប់ក្នុងស្រុករបស់កម្ពុជាផងដែរ (សូមមើល មាត្រា៣១ I CC) ។ មាត្រា១៨ I ២ ICCPR រួមមានសិទ្ធិក្នុងការអនុវត្តន៍ និងបង្ហាញនូវសាសនាជាសាធារណៈ ។

**ច្បាប់នេះចែងអំពីការដាក់កំហិតលើសិទ្ធិនេះ ។**

**តើអ្នកធ្វើច្បាប់ត្រូវបានអនុញ្ញាតឱ្យធ្វើការដាក់កំហិត សម្រាប់គោលបំណង ដែលបានចែងនៅក្នុងផ្នែកទី I នៃច្បាប់នេះឬទេ?**

មាត្រា១៨ III ICCPR អនុញ្ញាតដល់ការដាក់កំហិតលើសេរីភាពសាសនាសម្រាប់គោលបំណង ដើម្បីការពារៈ

- សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
- សុខភាព
- ប្រពៃណី/សីលធម៌ល្អ
- សិទ្ធិ និងសេរីភាពរបស់អ្នកដទៃ តែប៉ុណ្ណោះ ។

មាត្រា៤៣ II CC ក៏អនុញ្ញាតផងដែរ ដល់ការដាក់កំហិតលើសេរីភាពសាសនា សម្រាប់គោលបំណង ដើម្បីការពារៈ

- ជំនឿសាសនាដទៃ
- សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ប្រការនេះបានលើកឡើងនូវសំនួររួចមកហើយ ថាតើការដាក់កំហិត ដើម្បីការពារ "សេចក្តីសុខនៃជីវិតប្រចាំថ្ងៃ" ត្រូវបានអនុញ្ញាតដោយមាត្រាទាំងនេះដែរឬអត់ ។

យោងតាមការប្រើពាក្យសាមញ្ញ "សេចក្តីសុខនៃជីវិតប្រចាំថ្ងៃ" នេះមិនត្រូវបានលើកឡើងនៅក្នុងបញ្ជីរាយឈ្មោះនៃគោលបំណងនៃការដាក់កំហិតនៃមាត្រាទាំងពីរនេះទេ (១៨ III ICCPR, ៤៣ II CC) ។ ប៉ុន្តែប្រហែលជាច្បាប់នេះចង់និយាយអំពីគោលបំណងមួយក្នុងចំណោមគោលបំណងដែលបានពោល នៅក្នុងបញ្ជីរាយឈ្មោះនេះ ។ ដូច្នេះ តើច្បាប់នេះមានបំណងដើម្បីការពារអ្វី? ច្បាប់នេះជាក់ស្តែង មានបំណងការពារជំនឿលើព្រះពុទ្ធសាសនានៃប្រជាជនកម្ពុជាភាគច្រើន ។ មិនតែប៉ុណ្ណោះ វាក៏មានបំណងការពារពួកគេពីការរំខានដោយមិនសមរម្យពីសំណាក់សាសនទូតទាំងនោះផងដែរ ។

គោលបំណងនេះមិនទាក់ទងជាមួយសន្តិសុខសាធារណៈ ឬសុខភាពទេ ពីព្រោះច្បាប់នេះផ្តោតទៅលើតែជនណាដែលដើរដោយឯកជនទៅគោះទ្វារផ្ទះឯកជន ឬគ្រាន់តែសុំឱ្យប្រជាជននិយាយអំពីសាសនាជាមួយគាត់តែប៉ុណ្ណោះ ។ វាក៏មិនទាក់ទងជាមួយប្រពៃណីល្អដែរ ពីព្រោះពុំមានប្រពៃណីណាដែល បដិសេធសកម្មភាពបែបនេះឡើយ ។

ប៉ុន្តែការការពារ "សេចក្តីសុខនៃជីវិតប្រចាំថ្ងៃ" អាចជា ការការពារសិទ្ធិរបស់អ្នកដទៃពីការបំភិតបំភ័យ ការធ្វើទុក្ខបុកម្នេញ ឬការរំខានទាំងបំពាន (ឧទាហរណ៍ ដោយការគោះទ្វារខ្លាំងៗ ឬនៅពេលកំពុងគេងថ្ងៃ) ។

ការការពារ "សេចក្តីសុខនៃជីវិតប្រចាំថ្ងៃ" នៅក្នុងច្បាប់នេះ ក៏អាចមានបំណងការពារសាសនាព្រះពុទ្ធរបស់ប្រជាជនកម្ពុជាផងដែរ (សូមមើលមាត្រា៤៣ III CC ដែលប្រកាសថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ និងផ្តល់អាទិភាពដល់សាសនានោះ) ។ ដោយការនិយាយអំពីសាសនាផ្សេងមិន "ប៉ះពាល់" ដល់សាសនាព្រះពុទ្ធរបស់ប្រជាជនកម្ពុជានោះ ។ គោលបំណងនៃការការពារ មិនមែនការពារជំនឿលើព្រះពុទ្ធសាសនារបស់ពួកគេប្រឆាំងនឹងការប៉ុនប៉ងណាមួយ ដើម្បីកែប្រែសាសនានេះទេ ប៉ុន្តែគោលបំណងនៃការការពារនេះ គ្រាន់តែជាការការពារប្រឆាំងនឹងទម្រង់មិនសមស្របណាមួយនៃការប៉ុនប៉ងនោះតែប៉ុណ្ណោះ ដូចជា ការប្រឆាំងនឹងការប្រមាថមើលងាយ លើព្រះពុទ្ធសាសនា ឬការនិយាយបន្ទាបបន្ថោកព្រះពុទ្ធសាសនា ។

ដូច្នេះ គោលបំណងនៃច្បាប់នេះអាចស្របតាមរដ្ឋធម្មនុញ្ញ ប្រសិនបើគេមិនប្រកាន់ភ្ជាប់តឹងរឹងពេកនូវការប្រើពាក្យសាមញ្ញនៃគោលបំណងនៃច្បាប់នេះនៅក្នុងផ្នែកទី I នៃច្បាប់ អាចនឹងស្របនឹងរដ្ឋធម្មនុញ្ញ ។

**តើការដាក់កំហិតនៅក្នុងផ្នែកទី II សមាមាត្រឬទេ?**

ទេ ។ សមាមាត្រមានន័យថា ការដាក់កំហិតមិនត្រូវខ្លាំងលើសពីការចាំបាច់ឡើយ ។ នៅក្នុងករណីជាក់លាក់មួយ ការហាមប្រាមទាំងស្រុងលើសកម្មភាពទាំងអស់អាចធ្ងន់ធ្ងរពេក ។ ដើម្បីសម្រេចបំណងនៃការការពារសាសនាព្រះពុទ្ធ និងសិទ្ធិមិនត្រូវបានយាយី ធ្វើទុក្ខបុកម្នេញ ឬរំខានទាំងបំពាននោះ វាមិនចាំបាច់ហាមឃាត់រាល់សកម្មភាពទាំងអស់ឡើយ (ដូចបានកំណត់ក្នុងផ្នែកទី II) ។ ផ្ទុយទៅវិញ វាអាចគ្រប់គ្រាន់ ដើម្បីហាមឃាត់តែការរំខានទាំងបំពាន ដោយប្រើពាក្យសម្ដីអសុរោះ ឬប្រមាថមើលងាយ ឬការធ្វើសម្លេងបន្លាច ដោយការគោះទ្វារខ្លាំងៗ ឬការនិយាយបង្អាប់ ឬបន្ថោកព្រះពុទ្ធសាសនា ដូចជា ការចាត់ទុកសាសនានេះថាអន់ជាងសាសនាគ្រីស្ត ។

## សំនួរសិក្ខាធី ២០

សូមរៀបរាប់ បណ្ដាសិទ្ធិមនុស្សទាំងឡាយដែលអ្នកបានរកឃើញនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ព្រមទាំងបញ្ជាក់ឈ្មោះ និងដកស្រង់នូវមាត្រាដែលពាក់ព័ន្ធផង ។

ព្រមទាំងបញ្ជាក់ឈ្មោះនៃ**ការដាក់កំហិត**ទៅលើសិទ្ធិទាំងនោះ!

# សិទ្ធិមនុស្សដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ

| សិទ្ធិមនុស្ស | មាត្រា | ការដាក់កំហិត |
|---|---|---|
| សិទ្ធិស្មើភាពគ្នា<br>(សេរីភាពនៃការមិនរើសអើង)<br>• ភាពស្មើគ្នារវាងបុរស និង ស្ត្រី | មាត្រា៣១ II ១ CC<br><br>• មាត្រា៤៥ III CC | សិទ្ធិសេរីភាពរបស់អ្នកដទៃ<br>មាត្រា៣១ II ២ CC<br>- |
| សិទ្ធិរស់រានមានជីវិត<br><br>• សិទ្ធិមិនត្រូវទទួលរងនូវទារុណ្ណកម្ម | មាត្រា៣២ I CC<br><br>• មាត្រា៣៨ I CC | សិទ្ធិសេរីភាពរបស់អ្នកដទៃ<br>មាត្រា៣១ II ២ CC<br>- |
| សិទ្ធិមានសេរីភាពផ្ទាល់ខ្លួន<br>(សេរីភាពធ្វើសកម្មភាព) | មាត្រា៣២ I CC<br>មាត្រា៣៥ I CC | សិទ្ធិសេរីភាពរបស់អ្នកដទៃ<br>មាត្រា៣១ II ២ CC |
| សិទ្ធិមិនត្រូវបានគេដកហូតសញ្ជាតិកម្ពុជា | មាត្រា៣៣ I CC | - |
| សិទ្ធិបោះឆ្នោត | មាត្រា៣៤ I CC | LEMNA |
| សិទ្ធិធ្វើបដ្ឋនាលិខិត | មាត្រា៣៥ II CC | - |
| សេរីភាពក្នុងការប្រកបរបរអាជីវកម្ម<br><br>• សិទ្ធិក្នុងការលក់ផលិតផលរបស់ខ្លួន | មាត្រា៣៦ I CC<br><br>• មាត្រា៦០ I ១CC | តំរូវការរបស់សង្គម (មាត្រា៣៦ I ១CC)<br>"កាលៈទេសៈពិសេស"<br>មាត្រា៦០ I ២ CC |
| សិទ្ធិមានសេចក្តីថ្លៃថ្នូរជាមនុស្ស | មាត្រា៣៨ II CC | - |
| សិទ្ធិក្នុងការធ្វើបណ្តឹងទៅតុលាការ | មាត្រា៣៩ I ១CC និង<br>មាត្រា៣៨ VIII CC | - |
| សេរីភាពក្នុងការដើរហើរ | មាត្រា៤០ I CC | - |
| សិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និង<br>អាថិកំបាំងនៃការឆ្លើយឆ្លង | មាត្រា៤០ III CC | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| សេរីភាពក្នុងការបញ្ចេញមតិ | មាត្រា៤១ I ១CC | មាត្រា៤១ I ២ CC:<br>សិទ្ធិរបស់អ្នកដទៃ, ប្រពៃណីល្អរបស់សង្គម<br>ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ, សន្តិសុខជាតិ<br>ច្បាប់សារព័ត៌មាន |
| សេរីភាពក្នុងការបង្កើតសមាគម<br><br>• សិទ្ធិក្នុងការបង្កើតសហជីពកម្មករ<br>• សិទ្ធិធ្វើកូដកម្ម<br>• សិទ្ធិបង្កើតគណបក្សនយោបាយ | មាត្រា៤២ I ១CC<br><br>• មាត្រា៣៦ V CC<br>• មាត្រា៣៧ CC<br>• មាត្រា៤២ I ១ CC | សិទ្ធិសេរីភាពរបស់អ្នកដទៃ<br>មាត្រា៣១ II ២CC<br>ពង្រាងច្បាប់ស្តីពីសមាគម និងអង្គការ<br>ក្រៅរដ្ឋាភិបាល<br>• ច្បាប់ស្តីពីសហជីពកម្មករ<br>• ច្បាប់ស្តីពីបាតុកម្ម<br>• ច្បាប់ស្តីពីគណបក្សនយោបាយ |
| សេរីភាពក្នុងការជួបប្រជុំ | មាត្រា៤១ I CC | មាត្រា៤១ I ២CC:<br>សិទ្ធិរបស់អ្នកដទៃ, ប្រពៃណីល្អរបស់សង្គម<br>ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ, សន្តិសុខជាតិ |
| សេរីភាពខាងសាសនា | មាត្រា៤៣ I CC | មាត្រា៤៣ II CC:<br>សាសនារបស់អ្នកដទៃ, សណ្តាប់ធ្នាប់សាធារណៈ<br>សន្តិសុខសាធារណៈ |
| សិទ្ធិលើកម្មសិទ្ធិ | មាត្រា៤៤ I CC | មាត្រា៤៤ III CC:<br>ការដកហូតកម្មសិទ្ធិឯកជនអាចធ្វើបាន<br>លុះត្រាតែវាបំរើឱ្យប្រយោជន៍សាធារណៈ<br>និងមានសំណងដោយយុត្តិធម៌ |
| សិទ្ធិមានគ្រួសារមួយ | មាត្រា៤៧ CC | - |
| សិទ្ធិទទួលបានការអប់រំ | មាត្រា៤៦ I CC | - |

## សំនួរសិក្សាទី ២១

សូមបើកនូវ web-page: www.online.com.kh/users/kid ដូចខាងក្រោម:

→ បន្ទាប់មកចូល "**Related Links**",

→ រួចហើយ "**Legal Education**",

→ និងបន្ទាប់មកទៀតចូល

"**Human Rights Network International (HRNi Bruxelles)**" ។

សូមរក "សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីការកំចាត់ចោលរាល់នូវទំរង់នៃការមិនអនុគ្រោះ និងការរើសអើង ខាងវិស័យជំនឿ ឬសាសនា" ។

សូមដកស្រង់នូវមាត្រាពាក់ព័ន្ធដែលបញ្ញត្តិអំពីការកំហិតទៅលើសេរីភាពខាងសាសនា និងបញ្ជាក់ពីបណ្តាហេតុផលនានានៃការដាក់កំហិត ។

**មាត្រាដែលពាក់ព័ន្ធគឺមាត្រា១ ចំនុចទី៣**

**ហេតុផលនៃការដាក់កំហិតគឺ "សុវត្ថិភាពសាធារណៈ" , "សណ្តាប់ធ្នាប់សាធារណៈ" , "សុខុមាលភាពសាធារណៈ" , "សីលធម៌" និង "សិទ្ធិសេរីភាពជាមូលដ្ឋានរបស់អ្នកដទៃ"**

# សំនួរសិក្ខាទី ២២

ចូរបំពេញតារាងខាងក្រោម និងអនុវត្តជំនាញរបស់អ្នកក្នុងការផ្តល់មតិយោបល់លើច្បាប់!

| **មាត្រានៃពង្រាងច្បាប់ ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ** | **ការផ្តល់យោបល់វិភាគលើមាត្រានៃពង្រាងច្បាប់** (ចូរបំពេញយោបល់វិភាគរបស់អ្នកនៅទីនេះ) | **សំណើមាត្រាដែលត្រូវធ្វើវិសោធនកម្ម** (ចូរបំពេញសំណើវិសោធនកម្មរបស់អ្នក នៅទីនេះ) |
|---|---|---|
| **មាត្រា១១ កថាខ័ណ្ឌទី ១:** "ក្រសួងការពារជាតិ មានសមត្ថកិច្ចចេញប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់ អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទ ដល់កងយោធពល-ខេមរភូមិន្ទ។" | • តើស្ថិតនៅលក្ខខណ្ឌជាក់ស្តែងមួយណាដែល ក្រសួងការពារជាតិ មានសមត្ថកិច្ចចេញបណ្ណ័សំគាល់ប្រើប្រាស់អាវុធបាន? តើមានទីតិវិធីជាក់លាក់ណាមួយទេ?<br>• តើអាវុធនុយក្លេអែរ ជីវសាស្ត្រ និងគីមី អាចត្រូវទុកឱ្យកងយោធពលខេមរភូមិន្ទ ប្រើប្រាស់ដែរឬទេ? ដូច្នេះពាក្យថា "អាវុធគ្រប់ប្រភេទ" មានន័យទូលំទូលាយ និងមិនច្បាស់លាស់ទេ ។ | "ក្រសួងការពារជាតិ មានសមត្ថកិច្ចចេញប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់ អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ~~គ្រប់ប្រភេទ~~ **សាមញ្ញ** ដល់កងយោធពលខេមរភូមិន្ទ **ដើម្បីប្រើប្រាស់ក្នុងការហ្វឹកហាត់ និងការងារការពារជាតិ តែប៉ុណ្ណោះ**។" |
| **មាត្រា១២ កថាខ័ណ្ឌទី ៣:** "អាវុធទាំងអស់ ត្រូវចុះក្នុងបញ្ជី ហើយអាវុធគ្រប់ប្រភេទ ត្រូវតែស្តុកទុក និងបញ្ចូលក្នុងឃ្លាំងដែលមានសុវត្ថិភាព ។ ការលើកលែងករណីនេះអាចធ្វើទៅបានតាមរយៈប្រកាសអន្តរក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។" | • ការស្តុកអាវុធទុក គឺពាក់ព័ន្ធនឹងប្រយោជន៏សាធារណៈ ពីព្រោះ វាពាក់ព័ន្ធនឹងសន្តិសុខសាធារណៈ ។ ដូច្នេះ ការដែលអាចលើកលែងឱ្យមានការស្តុកអាវុធ ត្រូវតែបញ្ញត្តិដោយអ្នកធ្វើច្បាប់ មិនដោយក្រសួងការពារជាតិ ឬក្រសួងមហាផ្ទៃនោះទេ ។ ប្រតិភូកម្មអំណាចធ្វើច្បាប់ឱ្យទៅក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ជាការបំពានគោលការណ៏ នៃការបែងចែកអំណាច!<br>• តើអ្វីទៅជា"ឃ្លាំងមានសុវត្ថិភាព"? នេះជាពាក្យមានន័យមិនច្បាស់លាស់! | "អាវុធទាំងអស់ ត្រូវចុះក្នុងបញ្ជី ហើយអាវុធគ្រប់ប្រភេទ ត្រូវតែស្តុកទុក និង បញ្ចូលក្នុង *ឃ្លាំងដែលមានសុវត្ថិភាព* ។ ការលើកលែងករណីនេះ ~~អាចធ្វើទៅបានតាមរយៈប្រកាសអន្តរក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។~~ **អាចធ្វើទៅបានតែក្នុងកាលៈទេសៈណាដែលគេត្រូវការកំលាំងសន្តិសុខជាបន្ទាន់ ដើម្បីរក្សាការពារសន្តិសុខសាធារណៈ ។**" |
| **មាត្រា២០:** "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា៨ និង ១៤ នៃច្បាប់នេះ។" | តើការដាក់ទោសតឹងរឹង សមាមាត្រដែរឬទេ ចំពោះករណីមិនធ្ងន់ធ្ងរវិញនោះ ដូចជា ក្នុងករណីដែលមានការធ្វេសប្រហែស?<br>តើការប៉ុនប៉ងបំពានដោយអាវុធ វាធ្ងន់ធ្ងរដូចជាការបំពានដោយអាវុធតែម្តងដែរឬទេ? | "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា៨ និង ១៤ នៃច្បាប់នេះ ។ **ក្នុងករណីធ្វេសប្រហែសៈ ដាក់ពន្ធនាគារ ១៨ខែ និងករណីប៉ុនប៉ងៈ ដាក់ពន្ធនាគារ ២ឆ្នាំ ។**" |

# ការប្រលងបញ្ចប់វគ្គ

## សំនួរទី ១

តើធាតុសំខាន់ទាំង ៣ នៃដំណើរការធ្វើសេចក្តីសំរេចបែបលទ្ធិប្រជាធិបតេយ្យមានអ្វីខ្លះ?

ចូរឱ្យឧទាហរណ៍មួយ ចំពោះធាតុនីមួយៗ និងបញ្ជាក់ពីមាត្រាមួយនៃរដ្ឋធម្មនុញ្ញកម្ពុជា (CC) ដែលពាក់ព័ន្ធនឹងធាតុនីមួយៗនោះផង ។

១) **ការធ្វើជាតំណាង**នៃសមាជិកសង្គមទាំងអស់:

ឧទាហរណ៍: - តំណាងនៅក្នុងរដ្ឋសភាត្រូវតែធ្វើជាតំណាងប្រជាពលរដ្ឋកម្ពុជាទាំងអស់ មិនមែនតែមួយផ្នែកនៃពួកគេឡើយ មាត្រា៧៧ I CC ។

- អ្នកអាចរកមើលឧទាហរណ៍ដទៃទៀត នៅក្នុងឯកសារបង្រៀនដែលមានចំណងជើងថា "មុខងាររបស់អង្គនីតិបញ្ញត្តិ"

២) **តម្លាភាព** និង **សាធារណភាព** នៃដំណើរការធ្វើសេចក្តីសម្រេចចិត្ត

ឧទារហណ៍ : - បើកឱកាសឱ្យសាធារណជនចូលស្តាប់នៅក្នុងរដ្ឋសភា ឬព្រឹទ្ធសភា មាត្រា៨៨ I និង ១១១ I CC

៣) **ការពិភាក្សា** និង **ការជជែកគ្នា** :

ឧទាហរណ៍ : - មួយថ្ងៃក្នុងមួយសប្តាហ៍សម្រាប់សំនួរ និងចម្លើយនៅក្នុងរដ្ឋសភា មាត្រា៩៦ VI CC

## សំនួរទី ២

តើអ្នកតាក់តែងច្បាប់ ត្រូវតែធ្វើការពិចារណានៅពេលដែលពួកគេចង់បញ្ញត្តិការដាក់កំហិតលើសិទ្ធិមួយនៅក្នុងច្បាប់?

១) ទីមួយ អ្នកធ្វើច្បាប់ត្រូវតែគិតគូរពិចារណាថា ការដាក់កំហិតលើសិទ្ធិមនុស្សត្រូវគោរពតាម**គោលបំណងជាក់លាក់ណាមួយ** ដែលត្រូវបានអនុម័តដោយ**រដ្ឋធម្មនុញ្ញកម្ពុជា ឬអនុសញ្ញាអន្តរជាតិ** ។

២) ទីពីរ អ្នកធ្វើច្បាប់ត្រូវតែពិចារណាថា ការដាក់កំហិតលើសិទ្ធិមនុស្សនោះ**សមាមាត្រ** មានន័យថាការដាក់កំហិតនោះមិនត្រូវហួសក៏រិតនៃភាពចាំបាច់ឡើយ ។

## សំនួរទី ៣

មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលក្រុមប្រឹក្សាឃុំ សង្កាត់ មានខ្លឹមសារដូចតទៅនេះ:

"ក្នុងតួនាទីបំរើការងារមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ច:

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់
- លើកទឹកចិត្តឱ្យមានផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ"

តើអ្វីទៅជាបញ្ហាដែលមាននៅក្នុងអត្ថបទមាត្រានេះ? ចូររៀបរាប់អំពីបញ្ហានោះ និងពន្យល់ថាតើហេតុអ្វីបានជាវាជាបញ្ហា!

ពាក្យថា "សេវាសាធារណៈចាំបាច់" និង "ការពេញចិត្ត និង សុខុមាលភាពរបស់ប្រជាពលរដ្ឋ" មិនមាន **ភាពច្បាស់លាស់ឡើយ** ។

តើនៅពេលណាទើប សេវាទាំងនេះ "ចាំបាច់"? តើប្រជាពលរដ្ឋ "ពេញចិត្ត" នៅពេលណា? តើនៅពេលដែលពួកគេមានប្រាក់មួយលានដុល្លារ ឬក៏គ្រាន់តែនៅពេលដែលពួកគេមានផ្ទះសម្រាប់ជ្រកភ្លៀង?

ពាក្យមិនច្បាស់ទាំងនេះ បើកឱកាសឱ្យមានការបកស្រាយបែបអត្តនោម័តដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធររបស់ពួកគេ ។ ពួកគេបង្កើតទំនាស់ ច្រើនជាងដោះស្រាយទំនាស់ ។

គេមិនអាចទុកឱ្យអាជ្ញាធរ ឬតុលាការបំពេញនូវពាក្យមិនច្បាស់លាស់ទាំងនេះបានទេ ។ អ្នកធ្វើច្បាប់ផ្ទាល់ត្រូវតែធ្វើលំហាត់ និងបំពេញករណីយកិច្ចផ្នែកនីតិកម្មរបស់ពួកគេ ។ ពួកគេ ត្រូវផ្តល់នូវនិយមន័យច្បាស់លាស់ជាងនេះលើករណីយកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

ប្រសិនបើពួកគេមិនធ្វើដូច្នេះទេ ពួកគេបំពាន**គោលការណ៍នៃការបែងចែកអំណាច** ។

## សំនួរទី ៤

មាត្រា៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មានខ្លឹមសារ ដូចតទៅៈ

"តួនាទីមុខងារ និងអំណាចរបស់រដ្ឋបាលឃុំ-សង្កាត់ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រិត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។"

តើមាត្រានេះស្របនឹងរដ្ឋធម្មនុញ្ញដែរឬទេ? ចូរផ្តល់ហេតុផលសំរាប់ចំលើយរបស់អ្នក!

មិនត្រឹមត្រូវទេ ។ មាត្រានេះ **មិនស្របនឹងរដ្ឋធម្មនុញ្ញទេ** ។

មាត្រានេះ ទាក់ទងជាមួយ**ប្រតិភូកម្មអំណាចធ្វើបទបញ្ញត្តិ** ពីរដ្ឋសភា (អង្គនីតិបញ្ញត្តិ) ទៅក្រសួងមហាផ្ទៃ (អង្គនីតិប្រតិបត្តិ) ។ នៅក្នុងករណីបែបនេះ ការរំលោភដែលអាចកើតឡើងបានលើ**គោលការណ៍នៃការបែងចែកអំណាច** ត្រូវតែត្រួតពិនិត្យជានិច្ច ។

នៅក្នុងករណីនេះ មានការបំពានយ៉ាងច្បាស់លាស់លើគោលការណ៍នៃការបែងចែកអំណាច ពីព្រោះនិយមន័យនៃករណីយកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាការសំរេចចិត្តដែលសារៈសំខាន់បំផុត និងមានលទ្ធផលសំរាប់រយៈពេលយូរទៅអនាគត ដូច្នេះនិយមន័យបែបនោះ អាចធ្វើឡើងដោយរដ្ឋសភាតែប៉ុណ្ណោះ ។

## សំនួរទី ៥

តើសិទ្ធិរបស់អ្នកតាក់តែងច្បាប់ ក្នុងការបើកការពិភាក្សាជាសាធារណៈមួយនៅក្នុងរដ្ឋសភា ត្រូវបានការពារយ៉ាងដូចម្តេចដែរ? សូមកុំភ្លេចបញ្ជាក់អំពីមាត្រានានាដែលពាក់ព័ន្ធ!

១) **សិទ្ធិក្នុងការសាកសួរសមាជិករបស់រដ្ឋាភិបាល និងអាជ្ញាធរៈ** មាត្រា៩៥,៩៦,៩៧ CC និងប្រការ៣២ និង ៣៣ នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា

២) **សិទ្ធិក្នុងការនិយាយស្តីៈ** ប្រការ៥៤-៦១ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

៣) **សិទ្ធិទទួលបានអភ័យឯកសិទ្ធិៈ** មាត្រា៨0 II និង ១0៤ II ១ CC ។

## សំនួរទី ៦

តើរដ្ឋសភា និងព្រឹទ្ធសភា ខុសគ្នាត្រង់ណាខ្លះ?

១) រដ្ឋសភាមាន **អាសនៈចំនួន១២៣** ( មាត្រា៧៦ I CC) ព្រឹទ្ធសភាមាន**អាសនៈតែ៦១** ប៉ុណ្ណោះ ( មាត្រា៩៩ II CC)

២) សមាជិកសភាត្រូវតែមានអាយុយ៉ាងតិច ២៥ឆ្នាំ ( មាត្រា៧៦ IV CC) សមាជិកព្រឹទ្ធសភាត្រូវតែមានអាយុយ៉ាងតិច ៤0ឆ្នាំ ( មាត្រា៩៩ IV CC) ។

៣) សមាជិកសភាត្រូវបានជ្រើសតាំងដោយការបោះឆ្នោតដោយសេរី ជាសកល ដោយស្មើភាពគ្នា ដោយផ្ទាល់ និងជាសម្ងាត់ ( មាត្រា៧៦ II CC) ។ សមាជិកព្រឹទ្ធសភាបច្ចុប្បន្ន ត្រូវបាន**តែងតាំង**ដោយព្រះមហាក្សត្រ ( មាត្រា១៥៧ II CC) សមាជិកព្រឹទ្ធសភាក្រោយ នឹង**ត្រូវបានជ្រើសតាំងខ្លះ** ( តាមសន្លឹកឆ្នោតអសកល) **ត្រូវបានតែងតាំងខ្លះ** ( មាត្រា៩៩ III CC)

៤) អាណត្តិរបស់សភាជាតិមាន**រយៈពេល៥ ឆ្នាំ** ( មាត្រា៧៨ I CC) ។ អាណត្តិរបស់ព្រឹទ្ធសភាមាន**រយៈពេល ៦ឆ្នាំ** ( មាត្រា១០២ I CC) ។

៥) ខុសពីរដ្ឋសភា ព្រឹទ្ធសភាពុំមានអំណាចពិតប្រាកដ ដើម្បីធ្វើច្បាប់ និងដើម្បីជ្រើសរើស និងត្រួតត្រារដ្ឋាភិបាលឡើយ ។ ស្ថាប័ននេះអាចផ្តើមគំនិតបង្កើតច្បាប់ ( មាត្រា៩១ I CC) ប៉ុន្តែមិនអាចសាកសួរ ចោទប្រកាន់ ឬបដិសេធរដ្ឋាភិបាល ឬសមាជិករបស់រដ្ឋាភិបាលឡើយ ។

## សំនួរទី ៧

សកម្មភាពបញ្ចុះបញ្ចូល អាចសង្កត់ធ្ងន់លើ ៣ ផ្នែកខុសៗគ្នា:

- លើអ្នកតាក់តែងច្បាប់ផ្ទាល់
- លើដំណើរការតាក់តែងច្បាប់
- លើច្បាប់ដែលអនុម័តហើយ ។

ចូរផ្តល់នូវឧទាហរណ៍ចំនួន ២ លើសកម្មភាពបញ្ចុះបញ្ចូលនៅក្នុងផ្នែកនីមួយៗ ។

សំណើរខាងក្រោមសម្រាប់ការបញ្ចុះបញ្ចូលសកម្មភាពផ្សេងៗ ត្រូវបានផ្តល់ឱ្យនៅក្នុងប្រធានបទស្តីពី "ការបង្ការអំពើហឹង្សាក្នុងគ្រួសារ ":

**១) លើអ្នកធ្វើច្បាប់ខ្លួនឯង :**

- ធ្វើសម្ភាសន៍អ្នកធ្វើច្បាប់មកពីគណបក្សនីមួយៗ ដែលមានតំណាងនៅក្នុងរដ្ឋសភា អំពីមធ្យោបាយ ដែលពួកគេត្រូវបង្ការអំពើហឹង្សាក្នុងគ្រួសារ ។
- អញ្ជើញអ្នកធ្វើច្បាប់ទៅចូលរួមការពិភាក្សាក្នុងវេទិកាសេរី អំពីប្រធានបទ "ការបង្ការអំពើហិង្សាក្នុងគ្រួសារ" និងដើម្បីផ្តល់ពត៌មានដល់ពួកគេ ( ដូចជាអំពី ស្ថិតិ រឿងរ៉ាវរបស់ជនរងគ្រោះ ។ល។) ។

- ធ្វើបាតុកម្មនៅមុខរដ្ឋសភា ក្នុងកំឡុងសម័យប្រជុំ ខណៈដែលប្រធានបទស្តីពី "ការបង្ការអំពើហិង្សាក្នុងគ្រួសារ" ត្រូវបានពិភាក្សា ។
- រៀបចំកិច្ចប្រជុំមួយជាមួយគណៈកម្មការរដ្ឋសភាដែលពាក់ព័ន្ធ ដែលពិនិត្យមើល (ពង្រាង) ច្បាប់ មុនពេលដែល (ពង្រាង) ច្បាប់នេះត្រូវបានដាក់ជូនសភាទាំងមូល ។

**៣) លើច្បាប់ដែលបានអនុម័តហើយ ៖**

- ធ្វើការស្ទង់មតិអំពីចំណុចខ្សោយរបស់ច្បាប់ ហើយបោះពុម្ពផ្សាយលទ្ធផលរបស់វានៅក្នុងបណ្តាញសារព័ត៌មាន ។
- ធ្វើពាក្យបណ្តឹងជាសាធារណៈទៅក្រុមប្រឹក្សាធម្មនុញ្ញ ប្រសិនបើច្បាប់នោះមិនសមស្របតាមរដ្ឋធម្មនុញ្ញ ។

## សំនួរទី ៨

តើដំណាក់កាលសំខាន់ទាំង ៤ នៃដំណើរការតាក់តែងច្បាប់ រហូតដល់ច្បាប់ថ្មីមួយចូលជាធរមាននោះមានអ្វីខ្លះ?

១) ពង្រាងច្បាប់ថ្មី ឬពង្រាងវិសោធនកម្មលើច្បាប់ចាស់ត្រូវបាន**ផ្តួចផ្តើមគំនិត**រដ្ឋសភា, រដ្ឋាភិបាល ឬព្រឹទ្ធសភា, មាត្រា៩១ I ១។

២) បន្ទាប់មក ពង្រាងច្បាប់ ឬពង្រាងវិសោធនកម្មនោះត្រូវតែ**អនុម័ត**ដោយរដ្ឋសភា, មាត្រា៩0 CC ។

៣) ច្បាប់ដែលត្រូវបានអនុម័តនោះត្រូវការ**ប្រកាសឱ្យប្រើប្រាស់**ដោយព្រះមហាក្សត្រ, មាត្រា៩៣ I CC ។

៤) ហើយជាចុងក្រោយ ច្បាប់នេះត្រូវតែ**បោះពុម្ពផ្សាយ**ឱ្យចូលជាធរមាន, មាត្រា៩៣ II CC ។